# I. រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

### អនុក្រឹត្យលេខ ០១ អនក្រ.បក
### ស្ដីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០១នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍជនបទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្ដីពីច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីបង្កើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការរៀ និងការប្រព្រឹត្តទៅនៃធនាគារជាតិកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិ ទូទៅ នៃ សហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រាទី ១ ._ បង្កើតសហគ្រាសសាធារណៈដែលមានឧបនិស្ស័យសេដ្ឋកិច្ច និងមានឈ្មោះថា ធនាគារអភិវឌ្ឍន៍ជនបទ សរសេរជាភាសាអង់គ្លេស RURAL DEVELOPMENT BANK ។

www.pheakdeylaw.com

**មាត្រាទី ២ ._** គោលដៅចំបងរបស់ ធនាគារអភិវឌ្ឍន៍ជនបទ គឺជួយគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្មជនបទ និង សេដ្ឋកិច្ចទូទៅ ។

**មាត្រាទី ៣ ._** ភារកិច្ចចំបងរបស់ ធនាគារអភិវឌ្ឍន៍ជនបទ មានដូចតទៅ :

១. បង្កើតបណ្តាញស្ថាប័នហិរញ្ញវត្ថុឥណទាន និង ជួយលើកស្ទួយនូវក្របខ័ណ្ឌច្បាប់ សំរាប់សកម្មភាពក្នុងវិស័យនេះ ។

២. ធ្វើការជាធនាគារកំពូលដែលផ្តល់ឥណទាន ដើម្បីផ្តល់មធ្យោបាយចាំបាច់សំរាប់សកម្មភាពឥណទាន របស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

៣. ផ្តល់ហិរញ្ញប្បទាន ឬ ឥណទានវិនិយោគដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

៤. ផ្តល់ជំនួយបច្ចេកទេសលើការបណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

៥. អនុវត្តគ្រប់សកម្មភាព ជាអាណត្តិតាមការស្នើសុំរបស់រាជរដ្ឋាភិបាល ដែលធនាគារជាតិនៃកម្ពុជា ផ្តល់សិទ្ធិឲ្យគ្រប់គ្រងមូលនិធិសំរាប់ឥណទានក្នុងវិស័យនេះ ។

៦. ជាអ្នកផ្តល់ការប្រឹក្សាយោបល់ផ្នែកបច្ចេកទេសដល់ការគ្រប់គ្រងរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

៧. គ្រប់គ្រងបណ្តាញទីភ្នាក់ងារតាមខេត្ត និង ក្រុមហ៊ុនក្រោមឱវាទរបស់ធនាគារនេះ ។

៨. អនុវត្តគ្រប់ប្រតិបត្តិការធនាគារ ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ហិរញ្ញប្បទាន កិច្ចសន្យាផ្សេងៗ ដែលទាក់ទងដោយផ្ទាល់នឹងកម្មវត្ថុរបស់ខ្លួន ។

**មាត្រាទី ៤ ._** ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និង ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីប្រព័ន្ធធនាគារ ។

**មាត្រាទី ៥ ._** ដើមទុនដំបូងរបស់ធនាគារអភិវឌ្ឍន៍ជនបទមានចំនួន ១០.០០០.០០០.០០០រៀល (ដប់ពាន់លានរៀល) ជាសាច់ប្រាក់ទាំងអស់ ។

**មាត្រាទី ៦ ._** ទីស្នាក់ការកណ្តាលរបស់ធនាគារអភិវឌ្ឍន៍ជនបទ ស្ថិតនៅរាជធានីភ្នំពេញ ។

**មាត្រាទី ៧ ._** ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចតទៅ :

១. តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

២. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

៣. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក

៤. តំណាងក្រសួងកិច្ចការនារី ជាសមាជិក

៥. តំណាងធនាគារជាតិ នៃ កម្ពុជា ជាសមាជិក

៦. អគ្គនាយក របស់ធនាគារអភិវឌ្ឍន៍ជនបទ ជាសមាជិក

៧. តំណាងបុគ្គលិករបស់ ធនាគារអភិវឌ្ឍន៍ជនបទ ជាសមាជិកស្វ័យប្រវត្តិ

**មាត្រាទី ៨ ._** ធនាគារអភិវឌ្ឍន៍ជនបទត្រូវបានគ្រប់គ្រងដោយអគ្គនាយក១រូប ដែលតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលមតិពីប្រធានគណៈកម្មាធិការជាន់ខ្ពស់សំរាប់អភិវឌ្ឍន៍ជនបទ និងទេសាភិបាលនៃ ធនាគារជាតិ នៃកម្ពុជា ។

www.pheakdeylaw.com

សម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួន ត្រូវតែជូនដំណឹងជាមុនទៅក្រសួងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍ជនបទត្រូវបាន តែងតាំងតាមអនុក្រឹត្យតាមសំណើរបស់ក្រសួង ។

មាត្រាទី ៩ . ធនាគារអភិវឌ្ឍន៍ជនបទ អាចធ្វើប្រតិបត្តិការស្របទៅតាមលក្ខន្តិកៈរបស់ធនាគារជាតិនៃកម្ពុជាដែល ទាក់ទិននឹងខ្លួន ក្នុងការបង្កើតគណនីបញ្ញើ ឬកំចី ជាមួយធនាគារ មូលនិធិអភិវឌ្ឍន៍ ឬមូលនិធិ បរទេសផ្សេងៗទៀត ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន ។

មាត្រាទី ១០ . ធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានទទួលស្គាល់ជានីតិបុគ្គល មានសិទ្ធិធ្វើប្រតិបត្តិការពាណិជ្ជកម្ម ហើយ អាចដំណើរការអាជ្ញាប័ណ្ណធនាគារពាណិជ្ជ ដែលមានចែងក្នុងមាត្រាទី ៣ នៃច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

មាត្រាទី ១១ . ប្រធានធនាគារអភិវឌ្ឍន៍ជនបទមានតួនាទី សហការជាមួយស្ថាប័ន/ក្រុមហ៊ុនអន្តរជាតិ និង ស្ថាប័នឯកជនជាតិ និង បរទេស ដែលអាចផ្តល់ជំនួយឧបត្ថម្ភក្នុងការអភិវឌ្ឍន៍ ជនបទ ។

មាត្រាទី ១២ . លក្ខន្តិកៈរបស់ធនាគារអភិវឌ្ឍន៍ជនបទ ជាឧបសម្ព័ន្ធភ្ជាប់នឹងអនុក្រឹត្យនេះ ។

មាត្រាទី ១៣ . បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យ នេះត្រូវទុកជានិរាករណ៍ ។

មាត្រាទី ១៤ . សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី គ្រប់ក្រសួង-ស្ថាប័ន និងអភិបាលគ្រប់ខេត្ត-ក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់តាំងពី ថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១

សម្តេច នាយករដ្ឋមន្ត្រីទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការស្តារ និង អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

* * *

**អនុក្រឹត្យ លេខ ០២ អនក្រ.បក**

**ស្តីពីការបន្ថែមប្រាក់កំរៃគរុកោសល្យ ជូនបុគ្គលិកសិក្សា**

**នៃ ក្រសួងអប់រំយុវជន និង កីឡា**

* * * * * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

www.pheakdeylaw.com